# សន្ដរអាសនៈ

សារលិខិតរបស់សម្ដេចប៉ាប

ប្រ្វង់ស៊ីស្វ

សម្រាប់ទិវា សន្តិភាពពិភពលោកលើកទី៥៤

០១ មករា ២០២១

# វប្បធម៌នៃការយកចិត្តទុកដាក់
# ជាមាគ៌ាឆ្ពោះទៅរកសន្តិភាព

# សន្ដរអាសនៈ

## វប្បធម៌នៃការយកចិត្តទុកដាក់
## ជាមាគ៌ាឆ្ពោះទៅរកសន្តិភាព

# សន្តអាសនៈ

**សារលិខិតរបស់សម្តេចប៉ាប**
**ហ្វ្រង់ស៊ីស្កូ**

**សម្រាប់ទិវា សន្តិភាពពិភពលោកលើកទី៥៤**

**០១ មករា ២០២១**

# វប្បធម៌នៃការយកចិត្តទុកដាក់ ជាមាគ៌ាឆ្ពោះទៅរកសន្តិភាព

១) **ក្នុងឱកាសដើមឆ្នាំ២០២១នេះ** ខ្ញុំសូមជូនពរដោយគោរពជាទីបំផុត មកអស់លោកប្រមុខរដ្ឋ និងមកអស់លោកមេដឹកនាំរដ្ឋាភិបាល មកអស់លោកអ្នកទទួលខុសត្រូវអង្គការអន្តរជាតិ មកអស់លោកអ្នកដែលណែនាំសាសនានានា ព្រមទាំងមកសាសនិកនៃសាសនានានាផង មកទាំងបុរសនិងស្ត្រីៗដែលមានឆន្ទៈល្អ ។ ខ្ញុំក៏សូមជូនពរសព្វសាធុការដល់មនុស្សទាំងអស់ សូមឲ្យឆ្នាំខាងមុខនេះ អាចជួយមនុស្សជាតិឲ្យមានភាតរភាពកាន់តែជ្រៅទៅ គឺរវាងមនុស្សនិងមនុស្សក្នុងសហគមន៍នានា និងរវាងប្រជាជនទាំងឡាយនិងរដ្ឋអំណាចជងទាំងពួងដែរ ។

ឆ្នាំ២០២០ ជាឆ្នាំដែលមានជំងឺកូវីដ-១៩ ផ្តល់វិបត្តិយ៉ាងធ្ងន់ធ្ងរខាងសុខាភិបាល និងបានក្លាយទៅជាអភូតហេតុដែលមានសាខាជាច្រើន និងលទ្ធផលជាទូទៅធ្វើឲ្យកើតមានវិបត្តិនានាជាប់គ្នាយ៉ាងខ្លាំង ដូចជាវិបត្តិអំពីធម្មជាតិនៅជុំវិញយើង វិបត្តិស្បៀងអាហារ វិបត្តិសេដ្ឋកិច្ច និងមនុស្សផ្លាស់ប្តូរប្រទេស បណ្តាលឲ្យមានវិបត្តិធ្ងន់ និងបង្កើតទុក្ខវេទនាជាច្រើន ។ ជាពិសេស ខ្ញុំនឹកដល់អស់លោកអ្នកដែលបាត់បង់សមាជិកក្រុមគ្រួសារ ជាអ្នកដែលខ្លួនស្រឡាញ់ ។ ខ្ញុំក៏នឹកដល់អស់លោកអ្នក ដែលបាត់បង់ការងាររបស់ខ្លួនដែរ ។ ខ្ញុំក៏នឹកជាពិសេសដល់គ្រូពេទ្យ ដល់គិលានុប្បដ្ឋាក គិលានុប្បដ្ឋាយិកា ដល់អ្នកលក់ថ្នាំសង្កូវ ដល់អស់អ្នកដែលស្វែងរកថ្នាំវ៉ាក់សាំង ខ្ញុំក៏នឹកដល់អ្នកស្ម័គ្រចិត្តជួយគេ នឹកដល់អស់លោកព្រឹទ្ធាចារ្យដែលនៅជួយអ្នកជំងឺក្នុងមន្ទីរពេទ្យ និងក្នុងមណ្ឌលសុខភាពដែលថែទាំគេ និងនៅតែបន្តថែទាំគេដោយត្រូវអស់កម្លាំងយ៉ាងខ្លាំង និងបូជាជីវិត ។ អ្នកខ្លះក៏បានបូជាជីវិតដោយមានបំណងចង់នៅក្បែរអ្នកជំងឺ ឬចង់សង្គ្រោះជីវិតអ្នកជំងឺនេះ ។ ខ្ញុំសូមសរសើរអ្នកទាំងនោះ ហើយអង្វរសាជាថ្មី អស់លោកអ្នកដែលដឹកនាំនយោបាយ និងអស់លោកអ្នកដែលទទួលខុសត្រូវខាងអង្គការឯកជន សូមអស់លោកអ្នករកមធ្យោបាយសមគួរ ជានាឲ្យអស់អ្នកជំងឺ និងអស់អ្នកដែលក្រីក្រជាងគេ និងអស់អ្នកដែលខ្សោយជាងគេ អាចទទួលវ៉ាក់សាំងការពារជំងឺកូវីដ-១៩ និងបាត់ចែងឲ្យអ្នកជំងឺក្រីក្រ និងខ្សោយជាងគេអាចព្យាបាលបានផង ។ (១)

យើងព្រួយចិត្តដោយឃើញថា នៅជាមួយនឹងសក្ខីភាពនៃសេចក្តីអាណិតមេត្តា និងសាមគ្គីភាព ក៏មានអ្នកខ្លះនៅតែមានគំនិតជាតិនិយម ឬប្រកាន់ជាតិសាសន៍ ឬស្អប់ជនជាតិបរទេស ឬស្អប់សាសន៍ដទៃ អ្នកខ្លះក៏បង្កើត

សង្គ្រាមនិងជម្លោះ ដែលបណ្តាលឲ្យមានមនុស្សស្លាប់ជាច្រើន និងបណ្តាលឲ្យកើតអន្តរាយផ្សេងៗទៀតផង ។ សង្គ្រាមនិងជម្លោះនេះ ក៏កាន់តែមានកម្លាំងខ្លាំងឡើងដែរ ។

ព្រឹត្តិការណ៍ទាំងនោះនិងព្រឹត្តិកាណ៍ផ្សេងៗទៀតរបស់មនុស្សជាតិយើង ដែលបានកើតឡើងកាលពីឆ្នាំទៅមិញ បង្ហាត់បង្រៀនថា ចាំបាច់យើងត្រូវការបង្កើតការយកចិត្តទុកដាក់នឹងគ្នាទៅវិញទៅមក ដើម្បីសាងសង់សង្គមយើង លើទំនាក់ទំនងនៃភាតរភាពជាត្រើះ ។ ហេតុនេះហើយ បានជាខ្ញុំបានជ្រើសរើស **"វប្បធម៌នៃការយកចិត្តទុកដាក់ ជាមាគ៌ាឆ្ពោះទៅរកសន្តិភាព"** ទុកជាគោលជំហរនៃសារនេះ ។ មានតែវប្បធម៌នៃការយកចិត្តទុកដាក់ប៉ុណ្ណោះទេ ដែលអាចបំបាត់វប្បធម៌នៃការមិនអើពើ នៃការលះបង់បោល និងនៃការជំទាស់គ្នា ដែលមានស្ទើរតែជាទូទៅនៅសព្វថ្ងៃនេះ ។

## ២) ព្រះជាម្ចាស់ជាព្រះបង្កើតពិភពលោក បង្កើតមនុស្សឲ្យយកចិត្តទុកដាក់ថែរក្សាពិភពលោកនេះ

មានប្រពៃណីសាសនាជាច្រើន រៀបរាប់អំពីដើមកំណើតរបស់មនុស្សជាតិ ឬអំពីទំនាក់ទំនងជាមួយព្រះអង្គដែលបង្កើតគេមក និងអំពីទំនាក់ទំនងធម្មជាតិជាមួយមនុស្សលោកទាំងអស់ ។ ក្នុងគម្ពីរនៃគ្រីស្តសាសនា កណ្ឌកំណើតពិភពលោកសម្តែងថា តាំងពីដើមមកការយកចិត្តទុកដាក់លើគ្នាទៅវិញទៅមក មានសារៈសំខាន់ក្នុងព្រះគម្រោងការរបស់ព្រះជាម្ចាស់ សម្រាប់មនុស្សជាតិ ។ មានបញ្ជាក់ពីទំនាក់ទំនងរវាងមនុស្ស (លោកអាដាំ) និងដី (ភាសាហេប្រឺ អាដាម៉ា) និងបងប្អូនឯទៀត ។ ក្នុងព្រះគម្ពីរស្តីអំពីព្រះជាម្ចាស់បង្កើតពិភពលោក បាន

បញ្ជាក់ថា ព្រះអង្គប្រគល់សួននៅអេដែន (កណ ២:៨) ឲ្យអាដាំកាន់កាប់ ដោយមានភារកិច្ច ភ្ជួររាស់និងយកចិត្តទុកដាក់ថែរក្សា សួននេះ (កណ ២:១៥) ។ ការនេះមានន័យថា ម្យ៉ាងធ្វើឲ្យកើតផលឡើង ហើយម្យ៉ាងទៀតឲ្យថែរក្សាដី និងទុកឲ្យដីនៅមានសមត្ថភាពនឹងគាំទ្រជីវិត ។(២) កិរិយាស័ព្ទ ភ្ជួររាស់និងយកចិត្តទុកដាក់ថែរក្សា ពន្យល់ពីទំនាក់ទំនងរវាងលោកអាដាំ និងផ្ទះ(សួនច្បារ) របស់ខ្លួន ។ ក៏មានបញ្ជាក់ថា ព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់លើគាត់ ដោយប្រោសឲ្យគាត់ជាម្ចាស់ និងជាអ្នកយកចិត្តទុកដាក់លើអ្វីៗដែលព្រះអង្គបានប្រតិស្ឋានទាំងអស់មក ។

ក្រោយមកមានថែងពីលោកកាអ៊ីន និងលោកអេបិល ជាបងប្អូនដែលកើតរឿងជាមួយគ្នា ។ លោកកាអ៊ីនយល់ថា លោកត្រូវការពារខ្លួន គឺលោកមានគំនិតមិនល្អទេ ។ ក្រោយពីបានសម្លាប់អេបិលជាប្អូនមក លោកកាអ៊ីនតបឆ្លើយនូវសំណួររបស់ព្រះជាម្ចាស់ថា៖ តើខ្ញុំជាអ្នកយកចិត្តទុកដាក់លើប្អូនខ្ញុំឬ?(៣) បាទ! លោកកាអ៊ីន ពិតជាអ្នកយកចិត្តទុកដាក់ថែរក្សាប្អូនមែន! ។ "**ក្នុងរឿងពីបូរាណ គេបានសរសេរជានិមិត្តរូបយ៉ាងជ្រៅ។ មានសេចក្ដីជឿជាក់បានកត់ទុកនៅទីនេះ គឺអ្វីៗសុទ្ធតែជាប់គ្នា គឺការពារយ៉ាងពិតប្រាកដនៃការរស់នៅរបស់យើង ព្រមទាំងទំនាក់ទំនងជាមួយធម្មជាតិ មិនអាចបំបែកចេញពីភាតរភាពជាបងប្អូន ឬពីយុត្តិធម៌ និងពីភាពស្មោះត្រង់នឹងអ្នកដទៃ**" ។ (៤)

## ៣) ព្រះជាម្ចាស់ជាព្រះបង្កើតពិភពលោក ជាគំរូនៃការយកចិត្តទុកដាក់

ព្រះគម្ពីរតែងសម្ដែងពីព្រះជាម្ចាស់ ព្រះអង្គមិនគ្រាន់តែបង្កើតពិភពលោកប៉ុណ្ណោះទេ តែព្រះអង្គថែរក្សាអ្វីៗទាំងអស់ដែលព្រះអង្គបានបង្កើតមក ជាពិសេសលោកអាដាំ និងនាងអេវ៉ាព្រមទាំងបុត្រធីតារបស់គេ ។ ទោះបីព្រះអង្គដាក់បណ្ដាសាលោកកាអ៊ីន ព្រោះតែគាត់បានប្រព្រឹត្តឃាតកម្ម ក៏គាត់នៅតែទទួលព្រះអំណោយទានពីព្រះជាម្ចាស់ដែលបង្កើតគាត់ដែរ គឺព្រះអង្គប្រទានសញ្ញាសម្គាល់សម្រាប់ការពារគាត់ដើម្បីយកចិត្តទុកដាក់លើជីវិតរបស់គាត់ (កណ ៤:១៥) ។ ការណ៍នេះបញ្ជាក់ពីកិត្តិយស និងតម្លៃដែលមិនអាចរំលោភបានរបស់មនុស្ស ដែលព្រះជាម្ចាស់បានបង្កើតមក តាមព្រះរូបភាពព្រះអង្គ និងបានដូចព្រះអង្គ ។ ការណ៍នេះក៏ជាសញ្ញាសម្គាល់បង្ហាញព្រះគម្រោងការរបស់ព្រះជាម្ចាស់ដែលសព្វព្រះហឫទ័យ ការពារឲ្យសត្វលោកទាំងប៉ុន្មាន ដែលទ្រង់បានបង្កើតមក ព្រោះសន្តិភាពនិងហិង្សា មិនអាចនៅជាមួយគ្នាបានទេ ។(៥)

ការយកចិត្តទុកដាក់លើអ្វីៗដែលព្រះជាម្ចាស់បានបង្កើតមក ពិតជាត្រឹះតែងតាំងថ្ងៃសប្ប័ទ ។ ត្រូវតែងតាំងការគោរពព្រះជាម្ចាស់ ហើយត្រូវតែងតាំងរបៀបរស់នៅក្នុងសង្គម ដោយចាប់អារម្មណ៍នឹងអ្នកក្រីក្រ (កណ ១:១-៣; លវ ២៥:៤) ។ ការធ្វើពិធីមហាករុណាទិគុណក្នុងឱកាសឆ្នាំទីប្រាំពីរនៃឆ្នាំសប្ប័ទ ផ្ដល់ឲ្យគេឈប់ធ្វើសង្គ្រាម រំដោះទាសករឲ្យមានសេរីភាព និងលើកលែងបំណុលដល់អ្នកដែលជំពាក់ ។ ក្នុងឆ្នាំនៃមេត្តាករុណានោះ ឲ្យគេថែរក្សាអ្នកដែលខ្សោយជាងខ្លួន ដោយផ្ដល់យោបល់ថ្មីឲ្យគេអាចរស់នៅបាន កុំឲ្យមានអ្នកក្រីក្រក្នុងចំណោមប្រជាជន (ទក ១៥:៤) ។

គួរឲ្យសរសើរប្រពៃណីរបស់អស់លោកព្យាការី ដែលយល់ឃើញយុត្តិធម៌ដីកំពូល ។ តាមព្រះគម្ពីរបានបង្ហាញអំពីរបៀបដែលសហគមន៍អ៊ីស្រាអែលប្រព្រឹត្តចំពោះជនទន់ខ្សោយក្នុងចំណោមពួកគេ ។ ដូច្នេះ ព្យាការីអម៉ូស (២:៦-៨;៨) និងព្យាការីអេសាយ (៥៨) ដោយឡែក បានបន្លឺសំឡេងជាដរាបអំពីយុត្តិធម៌ចំពោះអ្នកក្រីក្រ ដែលព្រះជាម្ចាស់ទ្រង់ព្រះសណ្ដាប់និងថែរក្សា ព្រោះគេជាមនុស្សត្រូវរបួស និងគ្មានអំណាចទាល់តែសោះ (ទំន ៣៤:៧; ១១៣:៧៨) ។

## ៤) យកចិត្តទុកដាក់ ក្នុងកិច្ចការបម្រើរបស់ព្រះយេស៊ូ

ការរស់នៅនិងការប្រៀនប្រដៅរបស់ព្រះគ្រូយេស៊ូ ធ្វើឲ្យព្រះហឫទ័យអាណិតមេត្តារបស់ព្រះបិតាចំពោះមនុស្សលោក (យហ៣:១៦) កើតជារូបរាងហើយ ។ ក្នុងធម្មសាលានៅភូមិណាសារ៉ែត ព្រះគ្រូយេស៊ូបង្ហាញខ្លួនជាមនុស្សដែលព្រះអម្ចាស់បានតែងតាំង និងចាត់ឲ្យមក ដើម្បីនាំដំណឹងល្អជូនដល់អ្នកក្រីក្រ ប្រាប់ដល់អ្នកជាឈ្លើយថាគេនឹងមានសេរីភាព ប្រាប់មនុស្សខ្វាក់ថាគេនឹងមើលឃើញ និងរំដោះអ្នកដែលគេសង្កត់សង្កិនឲ្យមានសេរីភាព (លក ៤:១៨) ។ ព្រះរាជកិច្ចរបស់ព្រះមែស្ស៊ីនេះ ជាលក្ខណៈពិសេសក្នុងឆ្នាំមហាករុណាទិគុណ ជាសក្ខីភាពដែលច្បាស់ជាងគេអំពីបេសកកម្មដែលព្រះបិតាបានផ្ញើឲ្យលោក ។ ក្នុងចិត្តមេត្តាករុណាព្រះគ្រីស្តយាងមកជិតអ្នកជំងឺ ដោយមកជិតរូបកាយ និងរួមគំនិតរបស់គេ ហើយប្រោសគេឲ្យបានជាសះស្បើយគ្រប់គ្នា ។ ព្រះអង្គអត់ទោសឲ្យអ្នកបាប និងប្រទានឲ្យគេមានជីវិតថ្មី ។ ព្រះគ្រូយេស៊ូពិតជាគង្វាលដ៏ល្អដែលថែរក្សាកូនចៀមរបស់ខ្លួន (យហ ១០:១១-១៨; អគ ៣៤:១-៣១ ។ ព្រះអង្គក៏ជាអ្នកស្រុកសាម៉ារី ដែលមានចិត្តសប្បុរស ដែល

បន្ទាបខ្លួនលើមនុស្សដែលត្រូវរបួស មើលដំបៅគេ និងយកចិត្តទុកដាក់លើគេ (លក ១០:៣០-៣៧) ។

នៅកំពូលនៃបេសកកម្ម ព្រះគ្រីស្ទយេស៊ូបញ្ជាក់យ៉ាងច្បាស់ពីសេចក្តីអាណិតមេត្តាករុណារបស់ព្រះអង្គមានចំពោះយើង ដោយព្រះអង្គបូជាព្រះជន្មនៅលើឈើឆ្កាង ដើម្បីរំដោះយើងឲ្យរួចពីខ្ញុំនៃអំពើបាប និងនៃសេចក្តីស្លាប់ ។ ដោយបូជាព្រះជន្មនិងដោយយញ្ញបូជានោះ ព្រះអង្គបានបើកមាគ៌ានៃសេចក្តីអាណិតមេត្តា ហើយមានព្រះបន្ទូលដល់យើងម្នាក់ៗថា "**សូមដើរតាមខ្ញុំ ចូរធ្វើដូច្នេះចុះ!**" (លក ១០:៣៧) ។

## ៥) វប្បធម៌នៃការយកចិត្តទុកដាក់ ក្នុងជីវិតជាគ្រីស្តបរិស័ទ

កិច្ចការនៃមេត្តាករុណាទាំងខាងវិញ្ញាណ ទាំងខាងរូបកាយ ជាស្នូលនៃការបម្រើសេចក្តីអាណិតមេត្តារបស់ព្រះសហគមន៍ដើមដំបូង ។ គ្រីស្តបរិស័ទជំនាន់ដើមធ្លាប់ចែកទ្រព្យសម្បត្តិជាមួយគ្នា ហើយគ្មាននរណាម្នាក់ត្រូវខ្វះខាតឡើយ (កក ៤:៣៤-៣៥) ។ គេក៏ខិតខំធ្វើឲ្យព្រះសហគមន៍របស់គេ ទៅជាផ្ទះដែលសុខចិត្តទទួលគ្នា សុខចិត្តទទួលសភាពការណ៍របស់មនុស្ស សុខចិត្តជួយយកចិត្តទុកដាក់អ្នកដែលទន់ទាបជាងគេ ។ ដូច្នេះ គេយល់ថា គួរឲ្យប្រមូលតង្វាយដើម្បីជួយអ្នកក្រីក្រ ជួយបញ្ចុះសព ចិញ្ចឹមកូនកំព្រា ជួយអ្នកចាស់ជរា និងអ្នករងគ្រោះដោយអំភូតហេតុផ្សេងៗ ។ តែនៅពេលក្រោយ ចិត្តអាណិតមេត្តារបស់គ្រីស្តបរិស័ទបានបាត់កម្លាំងបន្តិច ។ មានលោកដែលបង្កើតព្រះសហគមន៍គួសសង្កត់ថា ព្រះជាម្ចាស់បានបង្កើតកម្មសិទ្ធិសម្រាប់ប្រើប្រាស់ជាសាធារណៈ ។ លោកអំប្រាស៍បញ្ជាក់ថា "ធម្មជាតិបានផ្សព្វផ្សាយអ្វីៗ

ទាំងអស់សម្រាប់មនុស្ស និងសម្រាប់ប្រើប្រាស់រួម ។ ហេតុនេះ ធម្មជាតិបានបង្កើតច្បាប់ទូទៅសម្រាប់មនុស្សទាំងអស់ តែចិត្តលោភលន់របស់អ្នកខ្លះ បានប្រែក្លាយសិទ្ធិនៃច្បាប់នេះសម្រាប់តែមនុស្សចំនួនតិច" ។ (៦) កាលអ្នកក្រៅគ្រីស្តសាសនា បៀតបៀនព្រះសហគមន៍នៅសតវត្សដើមដំបូងបានកន្លងផុតទៅ នោះព្រះសហគមន៍បានឆ្លៀតយកសេរីភាពនេះ បញ្ចូលគំនិតរបស់ខ្លួនក្នុងវប្បធម៌សង្គម ។ សេចក្តីត្រូវការនៅសម័យនោះ ទាមទារឲ្យគ្រីស្តបរិស័ទបង្ហាញពីសេចក្តីអាណិតមេត្តា ។ តាមប្រវត្តិសាស្ត្រ មានការរៀបរាប់កិច្ចការដ៏ច្រើនឥតគណនាអំពីសេចក្តីអាណិតមេត្តា ដោយគ្រីស្តបរិស័ទរួមគ្នាបង្កើតគ្រឹះស្ថានថ្មី សម្រាប់ជួយសម្រាលទុក្ខតាមសេចក្តីត្រូវការទាំងអស់របស់មនុស្ស គឺគេបង្កើតមន្ទីរពេទ្យ គេហដ្ឋានសម្រាប់អ្នកក្រីក្រ កន្លែងទទួលកូនកំព្រា ទទួលក្មេងៗ ទីជម្រកសម្រាប់អ្នកធ្វើដំណើរ និងរឿងឯទៀតផង ។(៧)

## ៦) គោលការណ៍នៃគោលលទ្ធិគ្រីស្តសាសនាក្នុងសង្គម ជាមូលដ្ឋានគ្រឹះនៃវប្បធម៌យកចិត្តទុកដាក់

ការបម្រើអ្នកក្រីក្រនៃព្រះសហគមន៍ដើមដំបូង ដោយមានការរិះគិតរបស់អស់លោកដែលកសាងព្រះសហគមន៍ជួយផង និងដោយមានសាក្សីជាច្រើនបានផ្ញើជីវិតលើព្រះគ្រីស្ត បានណែនាំឲ្យមានចិត្តអាណិតមេត្តាទៅជាស្នូលនៃលទ្ធិខាងសង្គមរបស់ព្រះសហគមន៍ ។ លទ្ធិខាងសង្គមរបស់ព្រះសហគមន៍នេះ ហាក់ដូចជាមរតកដ៏មានតម្លៃសម្រាប់អស់អ្នកដែលមានឆន្ទៈល្អ គឺជាគោលជំហរ ជាសេចក្តីសម្រាប់ជួយរិះគិតដើម្បីឲ្យយើងអាចយល់ថា ត្រូវជួយយកចិត្តទុកដាក់លើគេយ៉ាងដូចម្តេច គឺធ្វើឲ្យមនុស្សគ្រប់ៗរូបមានកិត្តិយស មានសាមគ្គីជាមួយអ្នកក្រីក្រ និងជាមួយអ្នក

ដែលគ្មានទីពឹង មានការយកចិត្តទុកដាក់នឹងប្រយោជន៍រួម និង មានការយកចិត្តទុកដាក់លើអ្វីៗទាំងអស់ដែលព្រះជាម្ចាស់បាន បង្កើតមក ។

**- ការយកចិត្តទុកដាក់ មានអត្ថន័យថា ឱ្យកិត្តិយសនិងសិទ្ធិ របស់មនុស្សម្នាក់ៗចម្រើនឡើង**

"គោលគំនិតរបស់មនុស្សម្នាក់ ជាបុគ្គល បានកើតនិងចម្រើន ឡើងក្នុងគ្រីស្តសាសនា ។ គោលគំនិតនេះជួយឲ្យគេចម្រើនឡើង ដោយពិត ឲ្យមានលក្ខណៈជាមនុស្ស ។ អ្នកដែលនិយាយពី "បុគ្គល" សម្តែងអំពីទំនាក់ទំនងជាមួយគេ តែមិនមែននិយាយពីម្នាក់ៗទេ ។ ពាក្យនេះបញ្ជាក់ពីការរួបរួមគ្នា មិនមែនបណ្តេញគេដោយឡែកទេ ។ ពាក្យនេះសម្តែងកិត្តិយសរបស់មនុស្ស ដែលគ្មាននរណាអាចរំលោភបាន ទេ តែគេមិនត្រូវជិះជាន់គេដើម្បីបានផលជាដាច់ខាត ។(៨) បុគ្គលម្នាក់ៗមានទីដៅផ្ទាល់ ហើយមិនដែលទៅជាឧបករណ៍ដែលគេវាយតម្លៃ ដោយគិតតែពីផលប្រយោជន៍របស់ខ្លួន ។ ព្រះជាម្ចាស់បានបង្កើតបុគ្គល ម្នាក់ៗ ដើម្បីឲ្យគេរស់នៅជាមួយអ្នកដទៃក្នុងក្រុមគ្រួសារ និងក្នុង សង្គម ។ ក្នុងសង្គម មនុស្សទាំងអស់មានកិត្តិយសស្មើគ្នា ។ ដោយកិត្តិយសនេះ មនុស្សមានសិទ្ធិ និងក៏មានភារកិច្ចរបស់គេដែរ ដែលរំឭកថា គេត្រូវទទួលខុសត្រូវ ហើយត្រូវលើកតម្កើងអ្នកក្រីក្រ អ្នកដែលមាន ជំងឺ អ្នកដែលមិនចូលក្នុងរបៀបធម្មតាក្នុងសង្គម ។ ម្នាក់ៗជាអ្នកជិតខាង ជិតឬឆ្ងាយ តាមទីកន្លែង ឬតាមពេលវេលា ។ (៩)

## - ការយកចិត្តទុកដាក់ថែរក្សាផ្ទះរួមរបស់មនុស្សជាតិ

"ការរស់នៅជាសង្គម តាមនយោបាយ ឬតាមសេដ្ឋកិច្ច ក្នុងគ្រប់ជំពូកបានពេញលក្ខណៈ នៅពេលណាមនុស្សទាំងអស់បម្រើប្រយោជន៍រួម គឺថា លក្ខ័ខណ្ឌខាងសង្គមដែលអាចឲ្យក្រុមនីមួយៗ និងឲ្យមនុស្សម្នាក់ៗក្នុងក្រុមទាំងនោះ បានពេញលក្ខណៈយ៉ាងស្រួល និងយ៉ាងពេញលេញ" ។(១០) ហេតុនេះហើយ ផែនការនិងការខិតខំរបស់យើង ត្រូវគិតគូរដល់លទ្ធផលនៅលើក្រុមមនុស្សជាតិនៅពេលឥឡូវនេះ ហើយនិងនៅពេលក្រោយ ។ ជាទូទៅ ជំងឺកូវីដ-១៩ បានបង្ហាញសេចក្តីពិតដែលនៅគ្រប់សម័យ គឺយើងបានទទួលស្គាល់ថា យើងទាំងអស់គ្នាដូចជាជិះសំពៅជាមួយគ្នា ទាំងទន់ខ្សោយនិងវង្វេងទិស ។ តែនៅពេលដដែលនោះ យើងទាំងអស់គ្នាមានសារសំខាន់ទាំងអស់គ្នា និងគេត្រូវការយើង គឺយើងទាំងអស់គ្នាត្រូវហៅឲ្យបែរទូករួមជាមួយគ្នា (១១) ព្រោះគ្មាននរណាអាចសង្គ្រោះម្នាក់ឯងបានទេ (១២) ហើយក៏គ្មានរដ្ឋ ឬជាតិណាអាចផ្តល់ប្រយោជន៍រួមឲ្យប្រជាជនខ្លួនបានដែរ ។ (១៣)

## - ការយកចិត្តទុកដាក់តាមរយៈសាមគ្គីភាព

"សាមគ្គីបញ្ជាក់យ៉ាងពិតប្រាកដនូវសេចក្តីអាណិតមេត្តាចំពោះអ្នកដទៃ មិនគ្រាន់តែជាមនោសញ្ចេតនាដ៏មិនច្បាស់លាស់ទេ តែជាការសម្រេចយ៉ាងមាំមួននិងព្យាយាម ចង់ធ្វើការដើម្បីជាប្រយោជន៍រួម គឺជាសម្រាប់ប្រយោជន៍របស់មនុស្សទាំងអស់ផង និងសម្រាប់ប្រយោជន៍មនុស្សម្នាក់ៗផងដែរ ដ្បិតយើងទាំងអស់គ្នាពិតជាមានការទទួលខុសត្រូវរបស់មនុស្សទាំងអស់" ។ (១៤) សាមគ្គីជួយយើងឲ្យសម្លឹងមើលអ្នក

ដទៃទៀត ជាបុគ្គលម្នាក់ ឬជាប្រជាជន ឬជាជាតិមួយ មិនមែនទុកជាអ្វីដែលត្រូវកត់ទុកក្នុងស្ថិតិ ឬទុកជាអ្វីដែលយើងអាចជិះជាន់យកផលចំណេញ និងដេញចោលកាលណាវាគ្មានប្រយោជន៍ទៀតទេ ។ តែយើងត្រូវរាប់គេទុកជាអ្នកដែលរស់នៅជិតយើង ជាមិត្តសម្លាញ់ដែលធ្វើដំណើររួមជាមួយយើង ជាអ្នកដែលព្រះជាម្ចាស់បានត្រាស់ហៅឲ្យរួមក្នុងពិធីជប់លៀងនៃជីវិត គឺព្រះជាម្ចាស់បានអញ្ជើញមនុស្សទាំងអស់ចូលក្នុងពិធីនេះដែរ ។

**- ការយកចិត្តទុកដាក់ និងការថែទាំអ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមក**

សារលិខិត សូមកោតសរសើរព្រះអង្គ ដោយយកចិត្តទុកដាក់យ៉ាងពេញលេញអំពីអ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមក បានជាប់ជាមួយគ្នា ។ សារលិខិតនេះក៏បញ្ជាក់អំពីភារកិច្ចជាចាំបាច់ ដោយស្តាប់សូរសម្រែករបស់អស់អ្នកដែលខ្វះខាត និងសូរសម្រែកនៃអ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមក ។ ប្រសិនបើ មនុស្សយកចិត្តទុកដាក់ស្តាប់សូរសម្រែកទាំងនេះជាអចិន្ត្រៃយ៍ នោះគង់តែនឹងកើតមានការយកចិត្តទុកដាក់លើផែនដីជាផ្ទះយើងនេះ រួមនិងអ្នកក្រីក្រផង ។ ត្រង់ប្រធានបទនេះ ខ្ញុំចង់និយាយសាជាថ្មីឡើងវិញថា "មនោសញ្ចេតនា ថាខ្លួនរួមយ៉ាងជិតស្និទ្ធជាមួយសត្វលោកទាំងអស់ក្នុងធម្មជាតិ អាចជាការពិតប្រាកដបាន លុះត្រាតែខ្លួននៅពេលដដែលមានចិត្តអាណិតមេត្តាយ៉ាងខ្លាំង មានមេត្តាករុណា និងយកចិត្តទុកដាក់ចំពោះមនុស្សទាំងអស់ទៀតផង ។ (១៥) "សន្តិភាព យុត្តិធម៌ និងការយកចិត្តទុកដាក់លើអ្វីដែលព្រះជាម្ចាស់បានបង្កើតមក ទាំងបីជាប់ជាមួយគ្នា ដែលមិនអាចបំបែកចេញពីគ្នាបាន ដើម្បីរកមធ្យោបាយដោះស្រាយមួយម្តងៗ ។ ដោះស្រាយមួយម្តងៗ

យើងមុខជាមិនឲ្យលាយឡំទាំងអស់ ។" (១៦)

## ៧) ត្រីវិស័យតម្រង់ឆ្ពោះទៅរកមាគ៌ារួម

សម័យនេះជាសម័យវប្បធម៌លះបង់ ។ ខ្ញុំឃើញមានភាពមិនស្មើគ្នាក្នុងជាតិនានា និងរវាងជាតិទាំងប៉ុន្មាន ។(១៧) ហេតុនេះ ខ្ញុំសូមអញ្ជើញអស់លោកអ្នកដែលទទួលខុសត្រូវអង្គការអន្តរជាតិ និងរដ្ឋាភិបាលទាំងអស់អ្នកទទួលខុសត្រូវលើពិភពលោកខាងសេដ្ឋកិច្ច ពិភពលោកខាងវិទ្យាសាស្ត្រ អ្នកទូរគមនាគមន៍ សង្គម អង្គការដែលអប់រំយុវជន ឲ្យយកត្រីវិស័យមួយនេះ គឺយកគោលជំហរដែលខ្ញុំបានរំឭកខាងលើ ទៅជាទីដៅរួម សម្រាប់ពិភពលោកដែលរួមគ្នាមានសេដ្ឋកិច្ចតែមួយ គឺទីដៅដែលមានលក្ខណៈជាមនុស្សយ៉ាងពិតប្រាកដ ។ (១៨) ការនេះ គង់តែជួយឲ្យយើងទទួលតម្លៃ និងកិត្តិយសជាបុគ្គលម្នាក់ៗ និងជួយឲ្យយើងធ្វើការរួមគ្នា ដោយមានសាមគ្គីរកប្រយោជន៍រួម ជួយសម្រាលទុក្ខអ្នកដែលរងទុក្ខដោយភាពក្រីក្រ មានជំងឺ ជាប់ជាទាសករ និងត្រូវគេប្រកាន់ជាតិសាសន៍និងត្រូវធ្លាក់ក្នុងសង្គ្រាម ។ ខ្ញុំក៏សូមឲ្យម្នាក់ៗទៅជាព្យាការី និងជាសាក្សីនៃវប្បធម៌ការយកចិត្តទុកដាក់ ដើម្បីបំបាត់ការមិនស្មើគ្នាជាច្រើនក្នុងសង្គម ។ ការនេះអាចកើតបានលុះត្រាតែស្ត្រីនិងបុរសនៃក្រុមគ្រួសារមនុស្សជាតិ និងមនុស្សទាំងអស់ក្នុងសង្គម តាមនយោបាយ ចូលរួមធ្វើការងារនេះជាមួយគ្នាយ៉ាងខ្លាំង ។

គោលជំហរនៃច្បាប់ខាងសង្គម ជាការចាំបាច់សម្រាប់បង្កើតវប្បធម៌នៃការយកចិត្តទុកដាក់ ។ គោលជំហរទាំងនោះបង្ហាញផ្លូវសម្រាប់ការទាក់ទងរវាងជាតិនានា ។ ភាពតរភាព ការគោរពគ្នាទៅវិញទៅមក សាមគ្គី និងការអនុវត្តតាមសិទ្ធិអន្តរជាតិ ត្រូវណែនាំក្នុងទំនាក់ទំនងទាំង

នោះ ។ តាមប្រធានបទនេះ ត្រូវបញ្ជាក់ម្ដងទៀតអំពីការការពារ និងការពង្រីកសិទ្ធិមនុស្សជាគ្រឹះដែលមិនអាចបំបាត់បាន ជាសិទ្ធិទូទៅក្នុងពិភពលោក និងមិនអាចបំបែកបានទេ ។ (១៩)

យើងក៏ត្រូវរំឭកថា ត្រូវគោរពសិទ្ធិមនុស្សធម៌ដែរ ជាពិសេសនៅពេលនេះដែលមានជម្លោះនិងសង្គ្រាមកើតតៗគ្នាដោយឥតឈប់ឈរសោះ ។ គួរឲ្យស្ដាយ មានតំបន់ជាច្រើននិងសហមគន៍ជាច្រើនមិននឹករឭកនូវពេលដែលគេរស់នៅក្នុងសន្តិភាព និងសេចក្ដីសុខសាន្ត ។ មានក្រុងជាច្រើនបានត្រឡប់ទៅជាមណ្ឌលអសន្តិសុខ គឺអ្នកក្រុងតវ៉ាដើម្បីសូមមានការងារធ្វើជាធម្មតា មានគ្រាប់រំសេវ មានកាំភ្លើងធំ តូច បាញ់បោះដោយមិនពិចារណា ។ ក្មេងៗពុំអាចទៅរៀនបាន ។ បុរសនិងស្ត្រីពុំអាចទៅធ្វើការដើម្បីចិញ្ចឹមក្រុមគ្រួសារ ។ ទុរភិក្សមាននៅកន្លែងដែលមិនធ្លាប់មានកាលពីមុន ។ មនុស្សត្រូវរត់បោលស្រុក មិនគ្រាន់តែទុកបោលនូវផ្ទះសម្បែងប៉ុណ្ណោះទេ តែលះបង់បោលប្រវត្តិសាស្ត្រនៃក្រុមគ្រួសារ និងឫសនៃវប្បធម៌ទៀតផង ។

មានមូលហេតុជាច្រើនដើម្បីវាយគ្នា តែលទ្ធផលនៅតែដដែលៗ គឺការបំផ្លាញ និងវិបត្តិខាងមនុស្សធម៌ ។ យើងត្រូវតែឈប់ដំណើរ ហើយសួរគ្នីគ្នាថា តើអ្វីខ្លះដែលណែនាំឲ្យពិភពលោកយល់ថា ជម្លោះគឺជាការធម្មតានៃពិភពលោកយើង? ហើយជាពិសេស តើយើងត្រូវប្រែចិត្ត និងមានគំនិតថ្មី ស្វែងរកសន្តិភាពយ៉ាងពិតប្រាកដដោយសាមគ្គី និងភាតរភាពទេ?

គេចាយធនធានច្រើនណាស់ដើម្បីសាស្ត្រាវុធ ជាពិសេសអាវុធបរមាណូ ។ (២០) គេអាចប្រើធនធានទាំងនោះទៅបំពេញអាទិភាពជា

សម្គាល់ដើម្បីមានសន្តិសុខដល់មនុស្ស ដូចជាការចម្រើនឡើងនៃសន្តិភាព និងការអភិវឌ្ឍមនុស្សលោកយ៉ាងពេញលេញ ការតវ៉ានឹងភាពក្រីក្រ និងការធានាពីសេចក្តីត្រូវការខាងសុខភាព ។ បញ្ហាសកលលោក ដូចជាជំងឺកូវីដ-១៩ និងការប្រែប្រួលអាកាសធាតុក៏ទាក់ទងនឹងសេចក្តីដដែលនេះដែរ ។ ត្រូវសម្រេចយ៉ាងក្លាហានថា និងប្រមូលប្រាក់ដែលគេប្រើសម្រាប់សាស្ត្រាវុធ និងការចំណាយខាងយោធាមកធ្វើជាមូលនិធិអន្តរជាតិដើម្បីបំបាត់ការស្រេកឃ្លានជាស្ថាពរ និងបន្តជួយឲ្យប្រទេសក្រីក្រជាងគេអាចចម្រើនឡើងបាន ។ (២១)

## ៨) ការអប់រំដើម្បី "វប្បធម៌នៃការយកចិត្តទុកដាក់"

ប្រសិនបើយើងចង់ឲ្យវប្បធម៌នៃការយកចិត្តទុកដាក់ចម្រើនឡើងត្រូវមានកម្មវិធីអប់រំគេ ។ គោលជំហរខាងសង្គម ពិតជាឧបករណ៍មួយដែលអាចទុកចិត្តបាន សម្រាប់សភាពការណ៍ផ្សេងៗ ។ ខ្ញុំសូមផ្តល់ឧទាហរណ៍ខ្លះៗអំពីរឿងនេះ៖

### - ការអប់រំគេឱ្យចេះយកចិត្តទុកដាក់

កើតក្នុងក្រុមគ្រួសារ ជាសភាពការណ៍គ្រឹះ និងជាធម្មជាតិនៃសង្គមជាកន្លែងដែលយើងរៀន ឲ្យរស់នៅដោយមានទំនាក់ទំនងជាមួយគ្នា និងរៀនឲ្យមានការគោរពគ្នាទៅវិញទៅមក ។ ប៉ុន្តែ ក្រុមគ្រួសារត្រូវទទួលសិទ្ធិបំពេញការងារនេះដែលជាជីវិត និងខានមិនបាន ។

### - កត្តាសំខាន់ក្នុងការអប់រំ

ដោយរួមជាមួយក្រុមគ្រួសារ គឺមានសាលារៀន និងមហាវិទ្យាល័យ ។

មានអ្នកធ្វើការខាងទូរគមនាគមន៍សង្គម ដែលមានមុខងារប្រហែលគ្នា (២២) ។ គេមានមុខងារណែនាំប្រព័ន្ធតម្លៃផ្សេងៗ ដែលសាងសង់លើការទទួលខុសត្រូវអំពីកិត្តិយសរបស់បុគ្គលម្នាក់ៗ របស់សហគមន៍ផ្សេងៗ សមាគមខាងភាសា ខាងជាតិសាសន៍ ខាងសាសនារបស់ប្រជាជននានា និងសិទ្ធិដែលហូរមកពីសម្ព័ន្ធតម្លៃនេះ ។ ការអប់រំពិតជាសរសរមួយដ៏ត្រឹមត្រូវ និងជាសាមគ្គីភាពក្នុងសង្គមយើង ។

**- សាសនា**

ជាទូទៅ និងជាពិសេសអស់លោកដឹកនាំសាសានា អាចបំពេញមុខងារមួយដែលដូរមិនកើត ដោយអស់លោកបញ្ជូនឲ្យសាសនិកជន និងឲ្យសង្គមនូវតម្លៃនៃសាមគ្គី និងការគោរពអ្នកដទៃដែលប្លែកពីខ្លួន ព្រមទាំងទទួលនិងយកចិត្តទុកដាក់លើបងប្អូនដែលខ្សោយជាងគេ ។ ខ្ញុំសូមរំឭកប្រសាសន៍របស់សម្តេចប៉ាប ប៉ូលទី៦ ចំពោះសភាប្រទេសអូហ្គង់ដា នៅឆ្នាំ១៩៦៩ ថា៖ កុំខ្លាចព្រះសហគមន៍! ព្រះសហគមន៍គោរពអស់លោក អប់រំប្រជាពលរដ្ឋឲ្យមានចិត្តទៀងត្រង់ និងនិយាយសេចក្តីពិត ។ ព្រះសហគមន៍មិនបង្កើតការប្រណែនឈ្នានីស ឬការបែកបាក់គ្នាទេ តែព្រះសហគមន៍ស្វែងរកឲ្យមានសេរីភាពដ៏ត្រឹមត្រូវ យុត្តិធម៌ក្នុងសង្គម និងសន្តិភាព ។ ប្រសិនបើព្រះសហគមន៍ចូលចិត្តមនុស្សមួយក្រុម បានសេចក្តីថា ព្រះសហគមន៍ចូលចិត្តអ្នកក្រីក្រ ចូលចិត្តការអប់រំអ្នកតូចតាចក្នុងចំណោមប្រជាជន និងយកចិត្តទុកដាក់លើអ្នកដែលរងទុក្ខ និងដែលគ្មាននរណាអើពើ” ។ (២៣)

ខ្ញុំសូមលើកទឹកចិត្តដល់អស់អ្នកដែលផ្ញើជីវិត អ្នកបម្រើប្រជាជនតាមរយៈអង្គការអន្តរជាតិ អង្គការក្នុងរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល

និងចំពោះអស់បងប្អូនដែលធ្វើការក្នុងវិស័យអប់រំ និងអ្នកស្វែងរកតាមមុខងាររបស់ខ្លួន ។ សូមឲ្យអាចទៅដល់គោលដៅនៃការអប់រំដែលបើកទៅរកពិភពលោក អាចស្តាប់គ្នាដោយចិត្តព្យាយាមឲ្យមានការសន្ទនាគ្នាដែលកសាង និងការយល់គ្នាទៅវិញទៅមក ។ (២៤) ខ្ញុំសូមឆ្លៀតឱកាសក្នុងសារអញ្ជើញដែលខ្ញុំផ្ញើទៅក្នុងការអប់រំទូទៅនេះ បានទទួលស្គាល់តទៅ ។

## ៩) គ្មានទេសន្តិភាព បើគ្មានវប្បធម៌នៃការយកចិត្តទុកដាក់

វប្បធម៌នៃការយកចិត្តទុកដាក់ ជាការផ្ញើជីវិតរួម ជាការសាមគ្គីនិងជាការរួមគ្នា ដើម្បីការពារនិងលើកតម្កើងកិត្តិយសនិងប្រយោជន៍រួមទាំងអស់ ។ ការនេះនាំឲ្យយកចិត្តទុកដាក់ និងបាប់អារម្មណ៍គឺឲ្យមានមេត្តាករុណា ឲ្យចេះជានានឹងគ្នា និងឲ្យបានជាសះស្បើយ ឲ្យគោរពគ្នាទៅវិញទៅមក និងឲ្យទទួលគ្នាទៅវិញទៅមក ។ គោលគំនិតនេះ ជាមាគ៌ាពិសេសសម្រាប់កសាងសន្តិភាព ។ ក្នុងពិភពលោកយើងនេះ មានកន្លែងជាច្រើន មានមាគ៌ាទៅរកសន្តិភាព ដែលណែនាំឲ្យរបួសបានជាសះស្បើយ ។ ការទាំងនេះមានប្រយោជន៍ណាស់ ។ យើងត្រូវការអ្នកកសាងសន្តិភាពដែលសុខចិត្តគិតគូរដោយប្រាជ្ញានិងចិត្តក្លាហាន ហើយតែងតាំងរបៀបឲ្យជាសះស្បើយ និងជួបជាមួយគ្នាបាន ។ (២៥)

ក្នុងពេលវេលានេះ ទូករបស់មនុស្សជាតិត្រូវខ្យល់សង្ឃរាបោកបក់យ៉ាងខ្លាំង ធ្វើដំណើរទៅមុខទាំងពិបាក ក្នុងការស្វែងរកជើងមេឃស្ងាត់ និងស្រឡះ ។ កិត្តិយសនៃបុគ្គល ជាគោលជំហរខាងសង្គម ជាគ្រឹះអាចជួយយើងឲ្យទៅរកកន្លែងរួម និងគ្មានគ្រោះកាច ។ ក្នុងឋានៈយើងជាគ្រីស្តបរិស័ទ យើងសម្លឹងមើលទៅព្រះនាងម៉ារី ជាផ្កាយនៃសមុទ្រ និងជា

ម្តាយនៃសេចក្តីសង្ឃឹម ។ ចូរយើងទាំងអស់គ្នារួមគ្នា ដើម្បីទៅកាន់ជើងមេឃថ្មី ដែលមានសេចក្តីអាណិតមេត្តា និងសន្តិភាព មានភាតរភាព និងសាមគ្គីភាព ជាកន្លែងយើងជួយគាំទ្រគ្នាទៅវិញទៅមក ។ យើងមិនដែលសុខចិត្តបាញ់ការល្បែង និងការមើលងាយអ្នកដទៃ ជាពិសេសអ្នកទន់ខ្សោយជាងគេ ។ យើងក៏មិនធ្លាប់បែរមុខចេញ (២៦) តែយើងផ្ចិតផ្ចង់ជារៀងរាល់ថ្ងៃយ៉ាងច្បាស់ ដើម្បីកសាងសហគមន៍ដែលមានសុទ្ធតែបងប្អូនទទួលគ្នាទៅវិញទៅមក ទាំងយកចិត្តទុកដាក់គ្នានឹងគ្នា ។ (២៧)

ពីបុរីវ៉ាទីកង់ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០

**សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ**